គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org
ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ថុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យឹម ប៉ូ
Mr. YIM Po អគ្គហិរញ្ញិក
និងនាយក CCPCR

លោក សុខ សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទីវ សារ៉ាយ៉េត
Ms. TIV Sarayet
សហនាយិកា WMC

លោក យ៉ង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សែន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម
Mr. Touch Tum
នាយក VIGILANCE

ស.ប្រ.ក/លេខ ០៤/០៧ គ.យ.ស.ប/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយ

## ពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧

*ភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧*

ខុមហ្វ្រែល បានធ្វើការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចមួយចំនួន មានទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ស៊ីធីអ៊ិន វិទ្យុជាតិកម្ពុជា FM96MHz វិទ្យុជាតិ AM918KHz (ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទាំង៤នេះ ត្រូវបានអង្កេតការផ្សាយ ចាប់ពីម៉ោង១៧:០០ ដល់ម៉ោង២៣:០០ ជារៀងរាល់ថ្ងៃ) វិទ្យុបារាំងអន្តរជាតិ វិទ្យុអាស៊ីសេរី និងវិទ្យុសំលេងសហរដ្ឋអាមេរិក (វិទ្យុអន្តរជាតិទាំងបីនេះត្រូវបានអង្កេតការផ្សាយនៅពេលល្ងាចជាខេមរៈភាសាជារៀងរាល់ថ្ងៃ) ។

សរុបលទ្ធផលនៃការអង្កេតខាងលើរកឃើញថា គណបក្សប្រជាជនកម្ពុជា ទទួលបានការផ្សព្វផ្សាយច្រើនជាងគេរហូតដល់ជិតពាក់កណ្តាល គឺ៤៧% (៥៥នាទី ៣២វិនាទី) នៃការផ្សាយពីគណបក្សនយោបាយទាំងអស់ ។ ភាគរយនៃការផ្សាយពីគណបក្ស សម រង្ស៊ី គឺ២០% (ស្មើនឹង២៣នាទី ៤៤វិនាទី) និងគណបក្ស នរោត្តមរណឫទ្ធិ ២០% (ស្មើនឹង២៣នាទី ៨វិនាទី) ។ គណបក្សហ៊្វុនស៊ិនប៉ិចបានទទួលការផ្សាយត្រឹមតែ៨% (៩នាទី ៤៤វិនាទី) ខណៈដែលគណបក្សនយោបាយ ៨ ទៀតរួមគ្នាត្រូវបានព្ទ និងផ្សព្វផ្សាយតែ៥% (៥នាទី ៥៧វិនាទី)ប៉ុណ្ណោះ ។ ការផ្សព្វផ្សាយ ភាគច្រើនមានន័យអព្យាក្រឹត ។ តែការផ្សព្វផ្សាយបែបវិជ្ជមានច្រើនលើសលប់មានចំពោះគណបក្សប្រជាជនកម្ពុជា ដែលមានរហូតដល់៦៩% ស្មើនឹង ៣៨នាទី ៣១វិនាទី ។

ដោយឡែកក្នុងប្រព័ន្ធផ្សព្វផ្សាយរដ្ឋ (ទទក វិទ្យុ FM 96MHz និង AM 918KHz) គណបក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយ៦៨% (ស្មើនឹង៩នាទី ៤៤វិនាទី) គឺលើសគណបក្សទាំង១១ផ្សេងទៀតបូកបញ្ចូលគ្នាទៅទៀត ហើយក៏មានតែគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលត្រូវបានផ្សព្វផ្សាយបែបវិជ្ជមានរហូតដល់ ៦២% (ស្មើនឹង៦នាទី៣វិនាទី) នៃរយៈពេលសរុបលើកឡើងពីគណបក្សនេះ ។ ការផ្សាយបែបអវិជ្ជមានមានចំពោះតែគណបក្សនយោបាយចំនួនបីប៉ុណ្ណោះ គឺគណបក្ស សម រង្ស៊ី គណបក្ស នរោត្តម រណឫទ្ធិ និងគណបក្ស ហ៊្វុនស៊ិនប៉ិច ដូចជាការផ្សព្វផ្សាយពីការលើកឡើងរបស់

សម្តេចនាយករដ្ឋមន្ត្រីដែលថា គណបក្សហ៊្វុនស៊ិនប៉ិចបានទាញយកផលប្រយោជន៍ដោយអយុត្តិធម៌ នៅក្នុងរាជរដ្ឋាភិបាលចំរុះជាដើម។

សំរាប់បណ្តាញទូរទស្សន៍កម្ពុជា(ស៊ីធីអិន) បានផ្សព្វផ្សាយតែគណបក្សប្រជាជនកម្ពុជាមួយប៉ុណ្ណោះក្នុងរយៈពេលអង្កេតដែលមានរយៈពេល ៣០នាទី ១៥វិនាទី។ មានកម្មវិធីពិសេសឈ្មោះ ទេពកោសល្យ និងស្នាដៃ របស់ប៉ុស្តិ៍នេះបានបង្ហាញពីស្នាដៃ និងសមិទ្ធិផលនានារបស់ចៅសង្កាត់មកពីគណបក្សប្រជាជនកម្ពុជាតែមួយប៉ុណ្ណោះ។

សំរាប់ការផ្សាយរបស់វិទ្យុអន្តរជាតិទាំងបីរួមគ្នា (វិទ្យុបារាំងអន្តរជាតិ វិទ្យុអាស៊ីសេរី និងវិទ្យុសំលេងសហរដ្ឋអាមេរិក) ទាក់ទងនឹងគណបក្សនយោបាយមានលក្ខណៈល្អប្រសើរ និងមានតុល្យភាពសំរាប់គណបក្ស នយោបាយចំនួន៤ (គណបក្ស ប្រជាជនកម្ពុជា គណបក្ស សម រង្ស៊ី គណបក្ស ហ៊្វុនស៊ិនប៉ិច និងគណបក្ស នរោត្តម រណឫទ្ធិ)ជាងប្រព័ន្ធផ្សព្វ-ផ្សាយនៅក្នុងស្រុកដែលត្រូវបានអង្កេត។ គណបក្ស សម រង្ស៊ី បាននាំមុខការផ្សាយដែលទទួលបាន៣១% (២៣នាទី ៤វិនាទី) បន្ទាប់មក គឺគណបក្ស នរោត្តម រណឫទ្ធិ ២៨% (២១នាទី ២៧វិនាទី) នៃរយៈពេលការផ្សាយពីគណបក្សនយោបាយទាំងអស់។ គណបក្ស ប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយ២១% (១៦នាទី ៣វិនាទី) និងគណបក្សហ៊្វុនស៊ិនប៉ិចបាន១២% (៩នាទី៤វិនាទី)។ ខណៈដែលគណបក្ស៣ផ្សេងទៀតរួមគ្នាត្រូវបានលឺ ៨% (៥នាទី ៣៨វិនាទី)។ ខ្លឹមសារនៃការផ្សាយក៏មានតុល្យភាពផងដែរ ដោយគណបក្សនយោបាយភាគច្រើនទទួលបានការផ្សព្វផ្សាយទាំងបែបវិជ្ជមាន អវិជ្ជមាន និងអព្យាក្រឹត។

បញ្ហាស្ត្រីក្នុងវិស័យនយោបាយត្រូវបានលើកឡើងយ៉ាងតិចតួចបំផុតត្រឹមតែ ៣នាទី ៣២វិនាទីប៉ុណ្ណោះ ដូចជាការលើកឡើងពីលោកជំទាវ ម៉ែន សំអន ក្នុងឱកាសទទួលសញ្ញាប័ត្របណ្ឌិតកិត្តិយសពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិជ្ជា ដោយមានការលើកឡើងពីស្នាដៃរបស់លោកជំទាវក្នុងការដឹកនាំ និងការប្រឡូកក្នុងវិស័យនយោបាយ ហើយត្រូវបានចាក់ផ្សាយដោយ ទទក។

ក្នុងពេលវេលាអង្កេតនេះ ស្ត្រីជាបេក្ខជនសំរាប់ឈរឈ្មោះបោះឆ្នោត ឬមេឃុំ ចៅសង្កាត់ជាស្ត្រីត្រូវបានផ្សព្វផ្សាយ ឬលើកឡើងតែក្នុងរយៈពេល ៤៨នាទី ៣២វិនាទីក្នុងឱកាសដែលអ្នកស្រីជំទប់ទីមួយឃុំល្បើក ស្រុកឈូក ខេត្តកំពត លើកឡើងពីបញ្ហាខ្លះៗ ដែលឃុំជួបប្រទះក្នុងការផ្សាយនាថ្ងៃទី៥ ខែកុម្ភៈរបស់វិទ្យុអាស៊ីសេរី។

ការលើកឡើងពីជនពិការក្នុងវិស័យនយោបាយមិនត្រូវបានផ្សព្វផ្សាយទេក្នុងរយៈពេលអង្កេត។

**លទ្ធផលនៃប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព**

ខុមហ្វ្រែលក៏អង្កេតប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពផងដែរ មានសារព័ត៌មានរស្មីកម្ពុជា និងកោះសន្តិភាព ទាក់ទងនឹងព័ត៌មាននយោបាយ ជាពិសេសទៅលើគណបក្សនយោបាយទាំង១២ ដែលឈរឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។

ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពផ្សព្វផ្សាយតែ៤គណបក្សប៉ុណ្ណោះមានគណបក្ស ប្រជាជនកម្ពុជា គណបក្ស សម រង្ស៊ី គណបក្ស ហ៊្វុន ស៊ិនប៉ិច និងគណបក្ស នរោត្តម រណឫទ្ធិ។ គណបក្ស ប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយច្រើនជាងគេគឺ ៦៦% (ស្មើនឹង២៥អត្ថបទ) និងភាគច្រើនក្នុងន័យវិជ្ជមាន។ ចំណែកគណបក្សបីទៀត គឺគណបក្ស សម រង្ស៊ី ១៣% (ស្មើនឹង៥អត្ថបទ) គណបក្សនរោត្តម រណឫទ្ធិ ១៣% (ស្មើនឹង៥អត្ថបទ) និងគណបក្ស ហ៊្វុនស៊ិនប៉ិច ៨% (ស្មើនឹង៣អត្ថបទ) ត្រូវបានផ្សព្វផ្សាយតិចតួចនិង ភាគច្រើនក្នុងខ្លឹមសារ អវិជ្ជមាន។

*ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដែលត្រូវបានអង្កេតនេះបានចាប់អារម្មណ៍តែទៅលើការផ្សាយពីគណបក្សធំៗទាំងបួនខាងលើប៉ុណ្ណោះខណៈដែលគណបក្សចំនួន៨ផ្សេង ទៀតរួមគ្នាត្រូវបានផ្សព្វផ្សាយដ៏តិចតួចប៉ុណ្ណោះ។*

សូមអរគុណ!

*សំរាប់ព័ត៌មានលំអិតសូមទាក់ទង:*


- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ០១២ ៨៤៥ ០៩១
- លោក **គុយ ចំនួនដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ០១២ ៨៤៦ ២១១